# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**និយ័តករគណនេយ្យនិងសវនកម្ម**

លេខ ០២២/២៣ ...........ន. គ. ស/សរ.ច.សា.ន

# សារាចរណែនាំ

## ស្តីពី

## លក្ខខណ្ឌ បែបបទ និងនីតិវិធី ក្នុងការទទួលបានអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម សម្រាប់គណនេយ្យករ និងសវនករ ជាជនបរទេស

យោងភាពចាំបាច់និងតម្រូវការសេវាគណនេយ្យនិងសវនកម្ម នៅក្នុងព្រះរាជាណាចក្រកម្ពុជា អនុលោមតាមច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម ប្រកាសលេខ១០៣ សហវ. ប្រក ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០ ស្តីពីការអនុញ្ញាតឱ្យគណនេយ្យករជំនាញ និងសវនករប្រតិស្រុតជាជនបរទេស មានសិទ្ធិបន្តចុះហត្ថលេខាលើរបាយការណ៍គណនេយ្យ និងរបាយការណ៍សវនកម្ម និង ប្រកាសលេខ០១៩ អ.ស.ហ.ប្រក. ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០២៣ ស្តីពីការគ្រប់គ្រងអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម **និយ័តករគណនេយ្យនិងសវនកម្ម (ន.គ.ស.)** សូមធ្វើការណែនាំចំពោះគណនេយ្យករនិងសវនករ ជាជនបរទេស ដែលបាននឹងកំពុងប្រកបវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម ឬបុគ្គលដែលមានបំណងចង់ស្នើសុំអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យ និងសវនកម្មនៅកម្ពុជា ត្រូវដាក់ពាក្យស្នើសុំមក **ន.គ.ស.** ដោយបំពេញលក្ខខណ្ឌដូចខាងក្រោម÷

**ក- លក្ខខណ្ឌសម្រាប់ការស្នើសុំអាជ្ញាបណ្ណលើកដំបូង (សម្រាប់គណនេយ្យករ ឬសវនករ ជាជនបរទេស)**

- ត្រូវមានវត្តមានក្នុងព្រះរាជាណាចក្រកម្ពុជារយៈពេល៦០(ហុកសិប) ថ្ងៃយ៉ាងតិច គិតត្រឹមថ្ងៃដាក់ពាក្យស្នើសុំចុះបញ្ជី និងត្រូវមានវត្តមានក្នុងព្រះរាជាណាចក្រកម្ពុជារយៈពេលលើសពី១៨២ (មួយរយប៉ែតសិបពីរ)ថ្ងៃ ក្នុងរយៈពេល ១២ (ដប់ពីរ)ខែ នៃខែណាមួយដោយគិតចាប់ពីថ្ងៃទទួលបានអាជ្ញាបណ្ណ
- មានសមាជិកភាពជាគណនេយ្យករជំនាញអាស៊ាន (សម្រាប់ជនបរទេសដែលមានសញ្ជាតិរបស់ប្រទេសជាសមាជិកអាស៊ាន)
- បានចុះបញ្ជីជាគណនេយ្យករជំនាញបរទេស (សម្រាប់ជនបរទេសដែលមានសញ្ជាតិរបស់ប្រទេសសមាជិកអាស៊ាន និងមិនមានសញ្ជាតិរបស់ប្រទេសជាសមាជិកអាស៊ាន)
- ជាសមាជិកសកម្ម របស់ **វ.គ.ស.ក.**
- បានប្រឡងជាប់មុខវិជ្ជាច្បាប់ស្តីពីពន្ធដារកម្ពុជា និងច្បាប់ស្តីពីអាជីវកម្មកម្ពុជា ពីស្ថាប័ន ឬវិទ្យាស្ថាន ដែលទទួលស្គាល់ដោយ **ន.គ.ស.**
- មានអាសយដ្ឋានស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជាច្បាស់លាស់ និងពិតប្រាកដ
- មិនធ្លាប់មានទោសទាំងនៅប្រទេសសាមី និងព្រះរាជាណាចក្រកម្ពុជា
- មិនធ្លាប់ប្រព្រឹត្តបំពានទៅនឹងក្រមសីលធម៌វិជ្ជាជីវៈ៣(បី) ឆ្នាំចុងក្រោយ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh. CAMBODIA.
គេហទំព័រ : www.acar.gov.kh
អ៊ីមែល : info@acar.gov.kh
ទូរស័ព្ទ ៨៥៥ - ២៣ ៨៨២ ១១១
Phone: 023 882 111

- មានប័ណ្ណការងារ និងសៀវភៅការងារជនបរទេស ដែលចេញដោយក្រសួងស្ថាប័នមានសមត្ថកិច្ច នៃព្រះរាជាណាចក្រកម្ពុជា
- បានបំពេញលក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវ និងសមស្រប (Fit and Proper test)
- បំពេញលក្ខខណ្ឌផ្សេងទៀតតាមការតម្រូវរបស់ **ន.គ.ស.**។

**ខ- លក្ខខណ្ឌសម្រាប់ការស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណ**

- ត្រូវមានវត្តមានក្នុងព្រះរាជាណាចក្រកម្ពុជា រយៈពេល៦០(ហុកសិប) ថ្ងៃយ៉ាងតិច គិតត្រឹមថ្ងៃដាក់ពាក្យស្នើសុំចុះបញ្ជីនិងត្រូវមានវត្តមានក្នុងព្រះរាជាណាចក្រកម្ពុជារយៈពេលលើសពី១៨២ (មួយរយប៉ែតសិបពីរ)ថ្ងៃ ក្នុងរយៈពេល ១២ (ដប់ពីរ)ខែ នៃខែណាមួយ ដោយគិតចាប់ពីថ្ងៃទទួលបានអាជ្ញាបណ្ណ
- បានចូលរួមកម្មវិធីអភិវឌ្ឍវិជ្ជាជីវៈបន្ត (CPD)តាមចំនួនម៉ោងដែលកំណត់ដោយ **វ.គ.ស.ក.** សម្រាប់រយៈពេល១២ខែចុងក្រោយ គិតត្រឹមថ្ងៃដាក់ពាក្យ
- បានចូលរួមវគ្គបណ្តុះបណ្តាលនានាដែលរៀបចំដោយ **ន.គ.ស.**
- មានសមាជិកភាពជាគណនេយ្យករជំនាញអាស៊ាន (សម្រាប់ជនបរទេសដែលមានសញ្ជាតិរបស់ប្រទេសជាសមាជិកអាស៊ាន)
- បានចុះបញ្ជីជាគណនេយ្យករជំនាញបរទេស (សម្រាប់ជនបរទេសដែលមានសញ្ជាតិរបស់ប្រទេសសមាជិកអាស៊ាន និងមិនមានសញ្ជាតិរបស់ប្រទេសជាសមាជិកអាស៊ាន)
- ជាសមាជិកសកម្ម របស់ **វ.គ.ស.ក.**
- មានអាសយដ្ឋានស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជាច្បាស់លាស់ និងពិតប្រាកដ
- មិនធ្លាប់មានទោស ទាំងនៅប្រទេសសាមី និងព្រះរាជាណាចក្រកម្ពុជា
- មិនធ្លាប់ប្រព្រឹត្តិបំពានទៅនឹងក្រមសីលធម៌វិជ្ជាជីវៈ
- មានប័ណ្ណការងារ និងសៀវភៅការងារជនបរទេស ដែលចេញដោយក្រសួង ស្ថាប័នមានសមត្ថកិច្ច នៃព្រះរាជាណាចក្រកម្ពុជា
- បានបំពេញលក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវ និងសមស្រប (Fit and Proper test)
- បំពេញលក្ខខណ្ឌផ្សេងទៀតតាមការតម្រូវរបស់ **ន.គ.ស.**។

**គ- ឯកសារភ្ជាប់**

**គ.១. រូបវន្តបុគ្គល**

- ប្រវត្តិរូបសង្ខេប (CV)
- លិខិតឆ្លងដែនមានសុពលភាពយ៉ាងតិច៦ (ប្រាំមួយ)ខែ និងឯកសារបញ្ជាក់ថាបានរស់នៅព្រះរាជាណាចក្រកម្ពុជា
- ឯកសារបញ្ជាក់ថាមានវត្តមានក្នុងព្រះរាជាណាចក្រកម្ពុជា រយៈពេល៦០ (ហុកសិប) ថ្ងៃយ៉ាងតិច គិតត្រឹមថ្ងៃដាក់ពាក្យ ស្នើសុំចុះបញ្ជីនិងត្រូវមានវត្តមានក្នុងព្រះរាជាណាចក្រកម្ពុជារយៈពេលលើសពី១៨២ (មួយរយប៉ែតសិបពីរ)ថ្ងៃ ក្នុងរយៈពេល ១២ (ដប់ពីរ)ខែ នៃខែណាមួយ ដោយគិតចាប់ពីថ្ងៃទទួលបានសិទ្ធិ
- លិខិតបញ្ជាក់ពី **វ.គ.ស.ក.** អំពីក្រមសីលធម៌វិជ្ជាជីវៈល្អ

- លិខិតបញ្ជាក់ពី **ន.គ.ស.** និង/ឬ ** វ.គ.ស.ក.** អំពីការបំពេញកម្មវិធីអភិវឌ្ឍន៍វិជ្ជាជីវៈបន្ត (CPD) សម្រាប់រយៈពេល ១២(ដប់ពីរ)ខែចុងក្រោយ គិតត្រឹមថ្ងៃដាក់ពាក្យស្នើសុំ
- វិញ្ញាបនបត្រគណនេយ្យករជំនាញអាស៊ាន
- វិញ្ញាបនបត្រចុះបញ្ជីគណនេយ្យករជំនាញបរទេស
- លិខិតឬវិញ្ញាបនបត្រសមាជិកសកម្មរបស់ **វ.គ.ស.ក**
- ព្រឹត្តិបត្រថ្កោលទោសច្បាប់ដើមមានសុពលភាពដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច របស់សាមីប្រទេស និងរបស់ប្រទេសកម្ពុជា
- មានប័ណ្ណការងារ និងសៀវភៅការងារជនបរទេស ដែលចេញដោយក្រសួង ស្ថាប័នមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា
- កិច្ចសន្យាជួលកន្លែងស្នាក់នៅ ដោយមានបញ្ជាក់ពីអាជ្ញាធរមូលដ្ឋាន
- សេចក្តីចម្លងសញ្ញាបត្រខ្ពស់បំផុត និងសញ្ញាបត្រគណនេយ្យករជំនាញ ដោយមានការបញ្ជាក់ត្រឹមត្រូវ
- ឯកសារពាក់ព័ន្ធផ្សេងទៀតតាមការស្នើសុំរបស់ **ន.គ.ស.** ។

**គ.២. នីតិបុគ្គល**

- ឯកសារបញ្ជាក់សាវតាក្រុមហ៊ុន និងរចនាសម្ព័ន្ធក្រុមហ៊ុន
- វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម លក្ខន្តិកៈក្រុមហ៊ុន និងសម្រង់ក្រុមហ៊ុន
- វិញ្ញាបនបត្រចុះបញ្ជីពន្ធដារ
- បណ្ណពន្ធប៉ាតង់
- លិខិត ឬវិញ្ញាបនបត្រសមាជិកសកម្មដែលចេញដោយ **វ.គ.ស.ក.**
- វិញ្ញាបនបត្រធានារ៉ាប់រងវិជ្ជាជីវៈ សម្រាប់អាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសវនកម្ម
- កិច្ចសន្យាជួលទីស្នាក់ការក្រុមហ៊ុន នៅមានសុពលភាព
- ផែនការអាជីវកម្ម រយៈពេល២ឆ្នាំយ៉ាងតិច
- ផែនការបណ្តុះបណ្តាលបុគ្គលិកខ្មែរដើម្បីក្លាយជាគណនេយ្យករជំនាញនិងសវនករ
- បញ្ជីឈ្មោះ និងប្រវត្តិរូបសង្ខេបរបស់នាយកសវនករ /ដៃគូសវនករ /សវនករប្រតិស្រុត និងមន្ត្រីជាន់ខ្ពស់របស់ក្រុមហ៊ុន
- ត្រូវមានយន្តការត្រួតពិនិត្យគុណភាពសវនកម្ម (នីតិវិធីសវនកម្ម សម្រាប់ក្រុមហ៊ុនសវនកម្ម) ដោយអនុលោមតាមស្តង់ដាទាក់ទងនឹងសវនកម្ម និងស្តង់ដាការអះអាងអន្តរជាតិនៃកម្ពុជា ព្រមទាំងស្តង់ដាពាក់ព័ន្ធផ្សេងទៀត ដែលមានជាធរមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា
- របាយការណ៍ហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទគណនេយ្យ២ (ពីរ)ឆ្នាំ ចុងក្រោយ ដោយអនុលោមតាមស្តង់ដាគណនេយ្យនិងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន
- អាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតប្រកបវិជ្ជាជីវៈគណនេយ្យ ឬសវនកម្មមានសុពលភាពដែលចេញដោយ **ន.គ.ស.** (ករណីក្រុមហ៊ុនធ្លាប់មានលិខិតអនុញ្ញាត)
- ឯកសារពាក់ព័ន្ធផ្សេងទៀតតាមការស្នើសុំរបស់ **ន.គ.ស.**។

**ឃ- សិទ្ធិ និងភារកិច្ចរបស់គណនេយ្យករ និងសវនករប្រតិស្រុតជាជនបរទេស**

បន្ទាប់ពីទទួលបានអាជ្ញាបណ្ណពី **ន.គ.ស.** គណនេយ្យករ និង សវនករប្រតិស្រុតជាជនបរទេស មានសិទ្ធិ និងកាតព្វកិច្ច ដូចបានកំណត់ក្នុង ប្រកាសលេខ០១៩ អ.ស.ហ.ប្រក. ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០២៣ ស្ដីពីការគ្រប់គ្រងអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម និងមានសិទ្ធិ និងកាតព្វកិច្ចបន្ថែមដូចខាងក្រោម÷

**ឃ.១. សិទ្ធិ**

- មានសិទ្ធិធ្វើជានាយកសវនករ /ដៃគូសវនករ /សវនករប្រតិស្រុត ដើម្បីសុំអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យ ឬ សវនកម្មក្នុងព្រះរាជាណាចក្រកម្ពុជា ដោយស្របច្បាប់
- មានសិទ្ធិចុះហត្ថលេខាលើរបាយការណ៍គណនេយ្យ ឬ/និង របាយកាណ៍សវនកម្ម។

**ឃ.២. កាតព្វកិច្ច**

- គោរពបានយ៉ាងខ្ជាប់ខ្ជួននូវក្រមសីលធម៌វិជ្ជាជីវៈសម្រាប់គណនេយ្យករជំនាញនិងសវនករប្រតិស្រុតកម្ពុជា និងស្តង់ដាបច្ចេកទេសពាក់ព័ន្ធជាធរមាន
- រាយការណ៍ជូន **ន.គ.ស.** អំពីការប្រែប្រួលនៃបុគ្គលិក ប្រចាំត្រីមាស
- រាយការណ៍ជូន **ន.គ.ស.** អំពីរយៈពេលអវត្តមានពីព្រះរាជាណាចកម្ពុជា
- ចុះហត្ថលេខាលើរបាយការណ៍គណនេយ្យ ឬ/និង របាយការណ៍សវនកម្មឯករាជ្យ និងឯកសារពាក់ព័ន្ធក្នុងនាមក្រុមហ៊ុន ដោយមានដាក់ឈ្មោះគណនេយ្យករឬសវនករ
- ប្រើប្រាស់បុគ្គលិកខ្មែរក្នុងចំនួនសមាមាត្រ អនុលោមតាមច្បាប់ស្តីពីការងាររបស់ព្រះរាជាណាចក្រកម្ពុជា
- បណ្តុះបណ្តាលបុគ្គលិកខ្មែរ ដើម្បីក្លាយជាគណនេយ្យករជំនាញ ស្របតាមផែនការដែលបានដាក់ចេញ
- រាយការណ៍ពីលទ្ធផលនៃការអនុវត្តផែនការបណ្តុះបណ្តាលប្រចាំឆ្នាំរបស់ខ្លួន មក **ន.គ.ស.** ជារៀងរាល់ឆ្នាំ ដើម្បីពិនិត្យនិងវាយតម្លៃ យ៉ាងយូរត្រឹមថ្ងៃទី១៥ ខែមករា នៃឆ្នាំបន្ទាប់
- ត្រូវផ្ញើរបាយការណ៍ប្រចាំត្រីមាស និងប្រចាំឆ្នាំ យ៉ាងយូរក្នុងសប្តាហ៍ទី៣ នៃត្រីមាស និងឆ្នាំបន្ទាប់ ដោយប្រើទម្រង់ដែលកំណត់ដោយ **ន.គ.ស.**
- ត្រូវសហការផ្តល់ព័ត៌មាននានាដែលតម្រូវដោយ **ន.គ.ស.**
- ត្រូវជូនដំណឹងមក **ន.គ.ស.** ក្នុងរយៈពេល១៥ថ្ងៃយ៉ាងយូរ ក្នុងករណីជាអាទិ៍÷
    - ការផ្លាស់ប្តូរនាយកសវនករ ដៃគូសវនករ សវនករ ឬគណនេយ្យករជំនាញក្នុងក្រុមហ៊ុន
    - ការសុំព្យួរអាជ្ញាបណ្ណ ឬការឈប់ប្រកបវិជ្ជាជីវៈដោយខ្លួនឯង
    - ការផ្លាស់ប្តូររចនាសម្ព័ន្ធម្ចាស់ភាគហ៊ុន
    - ការផ្លាស់ប្តូរអាសយដ្ឋានអាជីវកម្ម ឬមធ្យោបាយទាក់ទង។
- គោរព និងអនុវត្តតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាជាធរមានរបស់ព្រះរាជាណាចក្រកម្ពុជា។

**ង- ការចុះឈ្មោះជាគណនេយ្យករជំនាញបរទេស**

សម្រាប់រូបវន្តបុគ្គលដាក់ពាក្យស្នើសុំអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម សម្រាប់ជនបរទេស ត្រូវឆ្លងកាត់ **គណៈកម្មការត្រួតពិនិត្យនៃកម្ពុជា**។

**ច- ទោសទណ្ឌ**

រាល់ការមិនគោរពតាមលក្ខខណ្ឌតម្រូវ និងកាតព្វកិច្ចនានា តាមខ្លឹមសារនៃសារាចរណែនាំនេះ គណនេយ្យករ និងសវនករ ជាជនបរទេស និងនីតិបុគ្គលដែលមានគណនេយ្យករ និងសវនករ ជាជនបរទេស នឹងត្រូវព្យួរ ឬដកហូតអាជ្ញា-

បណ្ណប្រកបវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម ដោយមិនទាន់គិតដល់ទោសទណ្ឌផ្សេងទៀតដែលបានកំណត់នៅក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

**ឆ- ការអនុវត្ត**

គណនេយ្យករ និងសវនករ ជាជនបរទេស ត្រូវមកដាក់ពាក្យស្នើសុំអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម ដើម្បីប្រកបវិជ្ជាជីវៈគណនេយ្យ ឬប្រកបវិជ្ជាជីវៈសវនកម្ម ដោយគោរពតាមលក្ខខណ្ឌ និងបទប្បញ្ញត្តិ ដែលបានកំណត់ នៅក្នុងសារាចរណែនាំនេះ និងចាប់ផ្តើមបំពេញបែបបទ និងត្រូវយកចិត្តដាក់ក្នុងការអនុវត្តសារាចរណែនាំនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ៣កើត ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែមិថុនា ឆ្នាំ២០២៣

**អគ្គនាយក**

**ប៊ូ ថារិន**

<u>កន្លែងទទួល÷</u>

- ខុទ្ទកាល័យ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ស.ហ.វ. និងជាប្រធានក្រុមប្រឹក្សា អ.ស.ហ.

  **“ ដើម្បីគោរពជូនជ្រាប ”**

- វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា

  **“ ដើម្បី ជូនជ្រាបនិងសហការអនុវត្ត ”**

- ឯកសារ-កាលប្បវត្តិ